**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

**មន្ទីរអប់រំ យុវជន និងកីឡាខេត្តពោធិ៍សាត់**

**លេខ:..........✓..........អយកខ.**

# សេចក្តីជូនដំណឹង

## ស្តីពី

## ការផ្អាកដំណើរការបង្រៀន និងរៀន ជាបណ្តោះអាសន្ន ក្នុងឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់

យោង៖ - សភាពការណ៍តាមបណ្តោយព្រំដែនកម្ពុជា ថៃ

- អនុសាសន៍ណែនាំ ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។
- អនុសាសន៍ណែនាំ របស់ឯកឧត្តមអភិបាល នៃគណៈអភិបាលខេត្តពោធិ៍សាត់

មន្ទីរអប់រំ យុវជន និងកីឡាខេត្តពោធិ៍សាត់ សូមគោរពជម្រាបជូន គណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា លោកគ្រូ អ្នកគ្រូ អាណាព្យាបាល និងសិស្សានុសិស្សទាំងអស់ ជ្រាបថា៖ ក្រោយពីមានការឈ្លានពានពីសំណាក់យោធាថៃមកលើព្រំដែន នៃព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាក្នុងភូមិសាស្ត្រឃុំថ្មដា ស្រុកវាលវែង ខេត្តពោធិ៍សាត់វេលាម៉ោង ០៥:៣៦នាទីព្រឹក ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២៥ នេះ មន្ទីរអប់រំ យុវជន និងកីឡាខេត្តពោធិ៍សាត់ សម្រេចអនុញ្ញាតឱ្យគ្រឹះស្ថានសិក្សាទាំងអស់ ក្នុងឃុំថ្មដាដែលមាន៖សាលាបឋមសិក្សាថ្មដា សាលាបឋមសិក្សាច១ សាលាបឋមសិក្សាស្ទឹងមេទឹក និងអនុវិទ្យាល័យថ្មដា ផ្អាកដំណើរការបង្រៀន និងរៀនជាបណ្តោះអាសន្ន រហូតដល់មានការជូនដំណឹងជាថ្មី ដើម្បីធានាសុខសុវត្ថិភាពដល់ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សទាំងអស់ បញ្ចៀសបាននូវគ្រោះថ្នាក់ដែលបណ្តាលមកពីការបាញ់ប្លោងកាំភ្លើងធំរបស់ ភាគីថៃមកក្នុងទឹកដី នៃព្រះរាជាណាចក្រកម្ពុជា។

សេចក្តីដូចបានគោរពជម្រាបជូនដំណឹងខាងលើ សូមគណៈគ្រប់គ្រងគ្រឹះស្ថានសិក្សា លោកគ្រូ អ្នកគ្រូ អាណាព្យាបាល និងសិស្សានុសិស្សទាំងអស់ ជ្រាបជាព័ត៌មាន និងអនុវត្តប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃអង្គារ ៤រោច ខែមិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

ពោធិ៍សាត់ ថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២៥

**ចម្លងជូន៖**

- ក្រសួងអប់រំ យុវជន និងកីឡា
- រដ្ឋបាលខេត្តពោធិ៍សាត់
  "ដើម្បីជូនជ្រាបជាព័ត៌មាន"
- រដ្ឋបាលក្រុង ស្រុក"ដើម្បីអនុវត្ត"
- ឯកសារ
- កាលប្បវត្ត កា.រ.រដ្ឋបាល

អាសយដ្ឋាន: ក្រុងពោធិ៍សាត់ ខេត្តពោធិ៍សាត់ កម្ពុជា
ទូរស័ព្ទ: 052 740 857 / 012 373 888
អ៊ីមែល: pursat@moeys.gov.kh
គេហទំព័រ: www.moeys.gov.kh